ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សារលិខិតរំលែកទុក្ខ

**ជូនចំពោះ**

**ក្រុមគ្រួសារសព លោក ម៉ាន សាម៉ន**

ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីក្តុកក្តួល រន្ធត់ចិត្តឥតឧបមាដោយបានទទួលព័ត៌មានថា **លោក ម៉ាន សាម៉ន** ជំនួយការអមក្រសួងរ៉ែ និងថាមពល បានទទួលមរណភាព នៅថ្ងៃចន្ទ ២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ នៅវេលាម៉ោង ០៨:៣០នាទីព្រឹក ក្នុងជន្មាយុ៨០ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសប្រកបដោយក្តីខ្សឹកខ្សួលរំជួលចិត្ត ក្រៀមក្រំស្ទើររកទីបំផុតគ្មាននេះ ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមសម្តែងនូវសមានទុក្ខប្រកបដោយអនិច្ចលក្ខណធម៌ដ៏មហាជ្រាលជ្រៅ ព្រមទាំងក្តីសង្វេគដ៏មហាធំធេង និងពោរពេញដោយក្តីសោកស្តាយស្រណោះអាឡោះអាល័យជាអនេកប្បការចំពោះ **លោក ម៉ាន សាម៉ន** ដែលបានលាចាកលោក លាចាកពីក្រុមគ្រួសារ ព្រមទាំងលាចាកពីយើងខ្ញុំទាំងអស់គ្នា។

ជាថ្មីម្តងទៀត ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមលំឱនកាយឧទ្ទិសបួងសួងដល់វិញ្ញាណក្ខន្ធ **លោក ម៉ាន សាម៉ន** សូមបានចាប់បដិសន្ធិក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូម ក្រុមគ្រួសារនៃសព មេត្តាទទួលនូវមនោសញ្ចេតនាស្រឡាញ់រាប់អានដ៏ស្មោះពីខ្ញុំ។

ថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**